00687013

E86

# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception):
11 / 05 / 2011
ម៉ោង (Time/Heure) : 11:20
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: Ratanak

## អង្គជំនុំជម្រះសាលាដំបូង

**ជូនចំពោះ: ភាគីទាំងអស់នៃសំណុំរឿងលេខ ០០២** កាលបរិច្ឆេទ: ថ្ងៃទី ១១ ខែ ឧសភា ឆ្នាំ ២០១១

**ពី: ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន: លោក/លោកស្រីចៅក្រមទាំងអស់នៃអង្គជំនុំជម្រះសាលាដំបូង**
**និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ: កាលបរិច្ឆេទសវនាការបឋម**

យោងតាមដីការបស់អង្គជំនុំជម្រះ បង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ (ឯកសារលេខ E9) និងការបញ្ជាក់ជាបន្តបន្ទាប់របស់ភាគីអំពីបញ្ហាច្បាប់នានា នៅមុនពេលសវនាការបឋម (ឯកសារលេខ E9/23, E9/28, E9/30, E9/33 និង E9/34) ។

បន្ទាប់ពីអង្គជំនុំជម្រះបានពិចារណាទៅលើសេចក្តីសន្និដ្ឋានរបស់ភាគី ហើយដូចមានចែងក្នុងវិធាន ៨០ *ស្ទួន* នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះនឹងលើកយកបញ្ហាខាងក្រោមទៅពិចារណានៅក្នុងសវនាការបឋម ដែលមានដូចជា៖

- បញ្ហាបញ្ជីឈ្មោះសាក្សី និងអ្នកជំនាញ ដែលភាគីបានដាក់អនុលោមតាមវិធានផ្ទៃក្នុង។
- បញ្ហាអញ្ញត្រកម្មអនុលោមតាមវិធាន ៨៩ នៃវិធានផ្ទៃក្នុង។
- ការបញ្ជាក់ជាបឋមអំពីខ្លឹមសារនៃសំណងផ្លូវចិត្ត និងជាសមូហភាព ដែលសហមេធាវីនាំមុខមានបំណងទាមទារជាចុងក្រោយ អនុលោមតាមវិធាន២៣ស្ទួនបី អនុវិធាន (៣)(ខ) នៃវិធានផ្ទៃក្នុង។ សហមេធាវីនាំមុខនឹងត្រូវផ្តល់នូវឱកាសបន្ថែមទៀតក្នុងការបញ្ជាក់នូវបញ្ហាទាំងនេះ បន្ទាប់ពីអង្គបុរេជំនុំជម្រះសម្រេចទៅលើបណ្តឹងឧទ្ធរណ៍នៃពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរួច។

ក្នុងអំឡុងពេលសវនាការបឋម អង្គជំនុំជម្រះនឹងស្តាប់តែការលើកសំអាងហេតុផ្ទាល់មាត់ពាក់ព័ន្ធនឹងបញ្ហាដែលភាគីបានលើកឡើងខាងលើប៉ុណ្ណោះ ពីព្រោះអង្គជំនុំជម្រះយល់ឃើញថាបញ្ហាផ្សេងៗទៀត ភាគីបានលើកឡើងនៅក្នុងឯកសារនានាដែលបានដាក់ជូនចំពោះមុខអង្គជំនុំជម្រះ ដែលបញ្ហាទាំងនោះ៖

Nun

- ធ្លាប់ត្រូវបានអង្គជំនុំជម្រះសម្រេចម្តងរួចមកហើយ ក្នុងអំឡុងពេលនៃកិច្ចប្រជុំរៀបចំសវនាការ និងក្នុងសេចក្តីសម្រេចរបស់ខ្លួននៅពេលបន្ទាប់ (ឯកសារលេខ E74) ឬ
- នឹងស្ថិតក្រោមការណែនាំបន្ថែមពីសំណាក់អង្គជំនុំជម្រះនៅពេលក្រោយ ឬ
- ភាគីអាចលើកឡើងចំពោះមុខអង្គជំនុំជម្រះក្នុងអំឡុងពេលជំនុំជម្រះ ប្រសិនបើពាក់ព័ន្ធ និងចាំបាច់។

អង្គជំនុំជម្រះសូមបញ្ជាក់បន្ថែមថា ឯកសារលេខE74 គឺជាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលអាចប្តឹងសាទុក្ខដំណាលគ្នាជាមួយនឹងសាលក្រមលើអង្គសេចក្តីបាន អនុលោមតាមវិធានផ្ទៃក្នុង។

ដើម្បីជួយសម្រួលដល់ការរៀបចំផែនការ និងដើម្បីជូនដំណឹងជាមុនដល់ភាគីឱ្យបានឆាប់ជាអតិបរមានោះ អង្គជំនុំជម្រះសាលាដំបូងប្រកាសថា សវនាការបឋមនឹងប្រព្រឹត្តទៅនៅថ្ងៃ ចន្ទ ទី ២៧ ខែ មិថុនា ឆ្នាំ ២០១១ និងបន្តទៅថ្ងៃ អង្គារ ទី ២៨, ថ្ងៃ ពុធ ទី ២៩ និងថ្ងៃ ព្រហស្បត្តិ៍ ទី ៣០ ខែ មិថុនា ឆ្នាំ ២០១១ ក្នុងករណីចាំបាច់។ អាស្រ័យហេតុនេះ យើងសូមស្នើឱ្យភាគីធានាឱ្យប្រាកដថាខ្លួននឹងមានវត្តមានក្នុងអំឡុងពេលនេះ។

ពេលវេលា និងរបៀបវារៈលម្អិតជាងនេះនឹងជូនដំណឹងពេលក្រោយ នៅមុនពេលសវនាការបឋម ដែលតាមរយៈការជូនដំណឹងនោះ អង្គជំនុំជម្រះនឹងកំណត់ថា តើបញ្ហាណាខ្លះដែលអង្គជំនុំជម្រះទទួលយកជាអញ្ញត្រកម្ម ឬត្រូវស្តាប់ទឡ្ហីករណ៍ផ្ទាល់មាត់នៅពេលសវនាការបឋម។

អង្គជំនុំជម្រះសូមជម្រាបភាគី និងអង្គភាពនានាចំណុះឱ្យការិយាល័យរដ្ឋបាលនៃ អ.វ.ត.ក ជ្រាបថា ក្នុងអំឡុងខែ សីហា ឆ្នាំ ២០១១ អាចនឹងមានការកំណត់កាលបរិច្ឆេទនៃសវនាការបន្ថែមទៀតក្នុងសំណុំរឿងលេខ ០០២ ។ អាស្រ័យហេតុនេះ យើងសូមស្នើឱ្យភាគីធានាឱ្យប្រាកដថា ខ្លួននឹងមានវត្តមានក្នុងអំឡុងពេលនោះ ហើយធ្វើតាមការណែនាំនៃសេចក្តីជូនដំណឹងនេះនៅពេលកំណត់កាលបរិច្ឆេទឈប់សម្រាកប្រចាំឆ្នាំ និងការរៀបចំផែនការផ្សេងៗ។ សេចក្តីជូនដំណឹងបន្ថែមពាក់ព័ន្ធនឹងបញ្ហាទាំងនេះ និងបញ្ហាផ្សេងៗទៀត នឹងធ្វើនៅពេលក្រោយ។ ✓ Nu